Organized by

Supported by

# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

## Inside

### Infographic
"Cambodia-China Trade Statistics and Facts"

### Policy Brief
"Vocational Education and FDI Inflow:
A Cross-Country Panel Data Analysis of Asian and Latin-American Countries"
*Bun Vuthy*



វ៉ុល០៣ | លេខ០៤ | ខែមេសា ឆ្នាំ២០២៣
VOLUME 03 | ISSUE 04 | APRIL 2023

# ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម កម្ពុជា និងចិន

ព្រឹត្តិបត្រពាណិជ្ជកម្ម

រៀបចំដោយ

គាំទ្រដោយ

## ប្រកទីផ្សារចិន

កម្ពុជាទទួលបាន **អត្រាពន្ធអនុគ្រោះសម្រាប់ការនាំចេញ** ទៅកាន់ចិន ក្រោមក្របខ័ណ្ឌដូចខាងក្រោម:

- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា និងចិន (CCFTA) *ចូលជាធរមានថ្ងៃទី០១ ខែមករា ឆ្នាំ២០២២*
- កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់អាស៊ីប *ចូលជាធរមានថ្ងៃទី០១ ខែមករា ឆ្នាំ២០២២*
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-ចិន *ចូលជាធរមានក្នុងឆ្នាំ២០០៥*
- ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មផ្តល់ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក

## ពាណិជ្ជកម្មនិងវិនិយោគទ្វេភាគី

**១១១៩៤ លានដុល្លារ** ២០២១

**១១៦៨៦ លានដុល្លារ** ២០២២ ▲៤,៤%

ចិនបានក្លាយជា **ដៃគូពាណិជ្ជកម្មធំជាងគេ** របស់កម្ពុជា នៅក្នុងឆ្នាំ២០២២

ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា



ចិនបានក្លាយជា **ដៃគូមានវិនិយោគទុនច្រើនជាងគេ** នៅកម្ពុជា ឆ្នាំ២០២១ | **១៦៨៧ លានដុល្លារ** *(៤៨,២%)*

កម្ពុជាទទួលបានការវិនិយោគផ្ទាល់ពីបរទេសសរុប ប្រមាណ ៣,៥ ប៊ីលានដុល្លារក្នុងឆ្នាំ២០២១

ប្រភព៖ Financial Stability Review 2021 of National Bank of Cambodia

កម្ពុជា **នាំចេញទៅ** ចិន

- ១៥១០ លានដុល្លារ ២០២១
- ១២៤០ លានដុល្លារ ២០២២ *(-១៧,៩%)*

កម្ពុជា **នាំចូលពី** ចិន

- ៩៦៨៤ លានដុល្លារ ២០២១
- ១០៤៤៥ លានដុល្លារ ២០២២ *(+៧,៩%)*

## ក្រុមទំនិញនាំចេញ និងនាំចូលសំខាន់ៗ

● ការនាំចេញរបស់កម្ពុជាទៅចិន

● ការនាំចូលរបស់កម្ពុជាពីចិន

**ការនាំចេញរបស់កម្ពុជាទៅចិន**

- ផ្លែឈើ និងគ្រាប់ផ្លែឈើដែលអាចបរិភោគបាន **២០០ លានដុល្លារ**
- ធញ្ញជាតិ **១៦៣ លានដុល្លារ**
- ស្បែកជាប់រោម ស្បែកសិប្បនិម្មិត និងផលិតផលរបស់វា **១៥៦ លានដុល្លារ**
- ម៉ាស៊ីន និងឧបករណ៍អគ្គិសនី និងបំណែកភាគរបស់វា **១០២ លានដុល្លារ**
- សម្លៀកបំពាក់និងគ្រឿងបន្ទាប់បន្សំ ធ្វើឡើងពីក្រណាត់ចាក់ដោយម្ជុលពីរឬមួយ **៩៩ លានដុល្លារ**



**ការនាំចូលរបស់កម្ពុជាពីចិន**

- ផលិតផលបានពីការចាក់ដោយម្ជុល **១៦៩៩ លានដុល្លារ**
- ម៉ាស៊ីន និងឧបករណ៍អគ្គិសនី និងបំណែកភាគរបស់វា **៩៧៥ លានដុល្លារ**
- សរសៃអំបោះសិប្បនិម្មិតខ្លីៗ **៩៤៣ លានដុល្លារ**
- ម៉ាស៊ីន និងបរិធានមេកានិក; បំណែកភាគរបស់វា **៩០៩ លានដុល្លារ**
- វត្ថុធាតុប្លាស្ទិក និងវត្ថុធ្វើពីប្លាស្ទិក កៅស៊ូ និងវត្ថុធ្វើពីកៅស៊ូ **៦៦៦ លានដុល្លារ**

# CAMBODIA–CHINA
## TRADE STATISTICS AND FACTS

iTrade Bulletin

Organized by

Supported by

## CHINA MARKET ACCESS

Cambodia got **preferential tariff treatment on exports** to China via the following frameworks:

- Cambodia-China Free Trade Agreement (CCFTA)
  *entered into force on 01 Jan 2022*
- Regional Comprehensive Economic Partnership (RCEP)
  *entered into force on 01 Jan 2022*
- ASEAN-China Free Trade Agreement (ACFTA)
  *entered into force in 2005*
- The Generalized System of Preferences under the WTO framework

## BILATERAL TRADE & FOREIGN DIRECT INVESTMENT

11,194 million $ 2021

11,686 million $ ▲4.4% 2022

China became Cambodia's **largest trading partner** in 2022

Source: General Department of Customs and Excise



In 2021, China was the **largest investor** in Cambodia.

**1,687 million $** *(48.2%)*

Cambodia received foreign direct investment about $3.5 billion in 2021.

Source: Financial Stability Review 2021 of National Bank of Cambodia

Cambodia **exported to** China

| | |
|---|---|
| $ 1,510 million | 2021 |
| $ 1,240 million | 2022 *(-17.9%)* |

Cambodia **imported from** China

| | |
|---|---|
| $ 9,684 million | 2021 |
| $ 10,445 million | 2022 *(+7.9%)* |

## TOP IMPORTED & EXPORTED PRODUCTS GROUP

- Cambodia's Export to China
- Cambodia's Import from China



**Cambodia's Export to China**

- Edible fruits and nuts — **$ 200 million**
- Cereals — **$ 163 million**
- Furskins and artificial fur; manufactures thereof — **$ 156 million**
- Electrical machinery and equipment and parts thereof — **$ 102 million**
- Articles of apparel and clothing accessories, knitted or crochete — **$ 99 million**

**Cambodia's Import from China**

- Knitted or crocheted fabrics — **$ 1,699 million**
- Electrical machinery and equipment and parts thereof — **$ 975 million**
- Man-made staple fibres — **$ 943 million**
- Machinery and mechanical appliances; parts thereof — **$ 909 million**
- Plastics and articles thereof — **$ 666 million**

## IMF ថា កម្ពុជាឋិតក្នុងចំណោមប្រទេសសេដ្ឋកិច្ច អាស៊ាន ដ៏រឹងមាំបំផុតចំនួនបីនៅឆ្នាំនេះ

មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) រំពឹងថា កម្ពុជានឹងក្លាយជាប្រទេស ដែលមានសេដ្ឋកិច្ចសមិទ្ធកម្មល្អបំផុតនៅអាស៊ីប៉ូស៊ីហ្វិកនៅឆ្នាំនេះ រួមជាមួយប្រទេសហ្វីលីពីន និងវៀតណាម។ IMF បាននិយាយថា សេដ្ឋកិច្ចហ្វីលីពីនត្រូវបានគេព្យាករថានឹងមានកំណើន ៦,០% ដែលជាល្បឿនលឿនបំផុតក្នុងចំណោមសមាជិកទាំង ១៥ នៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាស៊ាន) ។ កម្ពុជាជាប់ចំណាត់ថ្នាក់លេខ២ស្មើនឹងវៀតណាម ដោយសេដ្ឋកិច្ចទាំងពីរត្រូវបានគេព្យាករថានឹងមានកំណើន ៥,៨%។ ការព្យាករចំពោះសមាជិកអាស៊ានដទៃទៀតមានដូចជា ចិន ៥,២% ឥណ្ឌូនេស៊ី ៥,០% ម៉ាឡេស៊ី ៤,៥% ឡាវ ៤,០% ថៃ ៣,៤% ប្រ៊ុយណេ ៣,៣% មីយ៉ាន់ម៉ា ២,៦% អូស្ត្រាលី ១,៦% កូរ៉េខាងត្បូងនិងប្រទេសសិង្ហបុរី ១,៥% ដូចគ្នា ជប៉ុន ១,៣% និង នូវែលសេឡង់ ១,១%។ IMF បានព្យាករថាសេដ្ឋកិច្ចពិភពលោកទាំងមូល នឹងមានកំណើន ២,៨% នៅឆ្នាំនេះ ដែលទាបជាងការធ្វើបច្ចុប្បន្នភាពខែមករាចំពោះការព្យាករក្នុងខែតុលាឆ្នាំមុន ០,១%។

*ប្រភព៖* Khmer Times

## ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាទៅកាន់កូរ៉េខាងត្បូងកើនឡើងជាង ១៤ ភាគរយ ក្នុងឆ្នាំ២០២២

ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាទៅកាន់កូរ៉េខាងត្បូង បានកើនឡើងពី ១៦៧,១៥ លានដុល្លារក្នុងឆ្នាំ២០២១ ដល់ ១៩១,៣៧ លានដុល្លារក្នុងឆ្នាំ២០២២ ដែលមានត្រាកំណើន ១៤,៣៧% ធៀបនឹងឆ្នាំមុន។ ការនាំចេញបានឈានដល់ ៤៣,១០ លានដុល្លារក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២៣ ជិតស្មើនឹងការនាំចេញចំនួន ៤៣,១១ លានដុល្លារក្នុងអំឡុងត្រីមាសទី៤ ឆ្នាំ២០២២។ ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាមានចំនួន ១៦៩,៧២ លានដុល្លារក្នុងឆ្នាំ២០២០ ១៨៧,៦៥ លានដុល្លារក្នុងឆ្នាំ២០១៩ និង ១៧៣,៨២ លានដុល្លារក្នុងឆ្នាំ២០១៨។ ប្រទេសកូរ៉េខាងត្បូងជាប់ចំណាត់ថ្នាក់លេខ១៣ ជាទីផ្សារនាំចេញសម្លៀកបំពាក់ធំបំផុតរបស់កម្ពុជា។ ការនាំចេញទៅកាន់កូរ៉េខាងត្បូងមានចំនួន ១,៣៧% (១៩១,៣៧ លានដុល្លារ) នៃការនាំចេញសរុបរបស់កម្ពុជាដែលមានចំនួន ១៣,៩៨ ប៊ីលានដុល្លារក្នុងឆ្នាំ២០២២។ ទន្ទឹមនឹងនោះ កម្ពុជាគឺជាអ្នកផ្គត់ផ្គង់សម្លៀកបំពាក់ធំជាងគេទី៧សម្រាប់ទីផ្សារកូរ៉េខាងត្បូង។ ការនាំចូលសម្លៀកបំពាក់ពីកម្ពុជាមានចំនួន ១,៥៧% នៃការនាំចូលសរុបដែលមានចំនួន ១២,១៨ ប៊ីលានដុល្លារក្នុងឆ្នាំ២០២២។ ការនាំចូលសម្លៀកបំពាក់របស់កូរ៉េខាងត្បូងភាគច្រើនមកពីប្រទេសចិន និងវៀតណាម ដែលបានផ្គត់ផ្គង់ ៦៤% នៃសម្លៀកបំពាក់ទៅកាន់ទីផ្សារកូរ៉េ។ *ប្រភព៖* Khmer Times

## ការនាំចេញអង្ករក្នុងត្រីមាសទីមួយកើនឡើង ១២៦លានដុល្លារ ខណៈការលក់នៅអឺរ៉ុបកើនឡើង

យោងតាមទិន្នន័យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានបង្ហាញថាក្នុងត្រីមាសទីមួយ ឆ្នាំ២០២៣ កម្ពុជាបាននាំចេញអង្ករក្នុងទំហំទឹកប្រាក់ ១២៦លានដុល្លារអាម៉េរិក ទៅកាន់ទីផ្សារបរទេស កើនឡើង ២០,៩លានដុល្លារអាម៉េរិក ឬប្រមាណ ១៩,៩% ធៀបនឹងឆ្នាំមុន។ លោក លុន យ៉េង អគ្គលេខាធិការសមាគមស្រូវអង្ករកម្ពុជា បានឱ្យដឹងថាការកើនឡើងប្រមាណ ២០% នេះ គឺជាទំហំទឹកប្រាក់នាំចេញ ខណៈដែលបរិមាណនាំចេញកើនឡើងតែ ១២% ប៉ុណ្ណោះ។ លោកបានបន្ថែមថា កំណើននាំចេញអង្ករកម្ពុជាក្នុងត្រីមាសទីមួយកើនឡើង ២០.០០០ តោន ដែលភាគច្រើនជាអង្ករក្រអូបនាំចេញទៅអឺរ៉ុប។ "ដោយសារអឺរ៉ុបទើបតែបើកទីផ្សារឡើងវិញ ដូចនេះអង្ករក្រអូបជាច្រើនត្រូវបាននាំចេញដោយមិនមានជាប់ពន្ធ។ ពីមុនវាមានការលំបាកក្នុងការលក់ តែបច្ចុប្បន្ន មានភាពងាយស្រួលជាងមុនព្រោះពន្ធដែលបានដាក់ពីមុនត្រូវបានបញ្ចប់នៅដើមឆ្នាំ២០២២ ហើយតម្លៃនៃការដឹកជញ្ជូនក៏ធូរជាងមុន"។ លោកបានលើកឡើងបន្តទៀតថាការដែលអង្ករក្រអូបកម្ពុជាទទួលបានចំណាត់ថ្នាក់ជាអង្ករល្អបំផុតក្នុងពិភពលោក នៅចុងឆ្នាំ២០២២ ក៏ជាកត្តាសំខាន់មួយទៀតដែលនាំឱ្យការនាំចេញអង្ករក្រអូបកម្ពុជាកើនឡើងផងដែរ។ *ប្រភព៖* Phnom Penh Post

## ទំហំពាណិជ្ជកម្មរវាងកម្ពុជានិងចិនក្នុងត្រីមាសទីមួយមានជិត ២,៩ប៊ីលានដុល្លារ ខណៈឱនភាពពាណិជ្ជកម្មកម្ពុជាថយចុះ

យោងតាមទិន្នន័យពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បានបង្ហាញថាទំហំពាណិជ្ជកម្មទំនិញរវាងកម្ពុជានិងចិនមានទំហំ ២,៨៦ប៊ីលានដុល្លារអាម៉េរិក គិតត្រឹមត្រីមាសទីមួយ ឆ្នាំ២០២៣ ថយចុះ ០,៣៨% ធៀបនឹងឆ្នាំមុន ខណៈការនាំចូលពីទីផ្សារចិនមានទំហំ ៨៨,៥២% នៃចំណែកទីផ្សារសរុប ថយចុះ ០,២៨%។ ពីខែមករាដល់មីនា កម្ពុជានាំចេញទំនិញទៅចិនមានទំហំ ៣២៨,៦៤លានដុល្លារអាម៉េរិក ធៀបនឹងឆ្នាំមុន ៣២១,៧៨លានដុល្លារអាម៉េរិក កើន ២,១៣% ខណៈកម្ពុជានាំចូលទំនិញពីចិនមានទំហំ ២,៥៣ប៊ីលានដុល្លារអាម៉េរិក ធៀបនឹងឆ្នាំមុន ២,៥៥ប៊ីលានដុល្លារអាម៉េរិក ថយចុះ ០,៧០%។ ការណ៍នេះបានធ្វើឱ្យឱនភាពពាណិជ្ជកម្មរវាងកម្ពុជាជាមួយចិនថយចុះប្រមាណ ១,១១% ពីទំហំ ២,២៣ប៊ីលានដុល្លារអាម៉េរិកមកត្រឹម ២,២០ប៊ីលានដុល្លារអាម៉េរិក។ ក្នុងត្រីមាសទីមួយនេះ ចិនជាប្រទេសធំទីមួយដែលកម្ពុជានាំចូលទំនិញ និងជាប្រទេសធំទីបួនដែលកម្ពុជានាំចេញទំនិញ បន្ទាប់ពីអាម៉េរិក (១,៨២ ប៊ីលានដុល្លារអាម៉េរិក) វៀតណាម (៩០៩,៨០លានដុល្លារអាម៉េរិក) និងថៃ (៣៣៤,១៦លានដុល្លារអាម៉េរិក)។ *ប្រភព៖* Phnom Penh Post

## Cambodia among Three Most Robust RCEP Economies This Year, Says IMF

The International Monetary Fund (IMF) expects Cambodia to be among the best-performing economies in East Asia and the Pacific this year alongside the Philippines and Vietnam. The IMF said the Philippine economy was forecast to expand 6.0 percent – the fastest pace among the 15 members of the Regional Comprehensive Economic Partnership (RCEP) agreement. Cambodia ranked equal second with Vietnam, with both economies projected to grow 5.8 percent. Other projections were 5.2 percent for China, 5.0 percent for Indonesia, 4.5 percent for Malaysia, 4.0 percent for Laos, 3.4 percent for Thailand, 3.3 percent for Brunei, 2.6 percent for Myanmar, 1.6 percent for Australia, 1.5 percent for both South Korea and Singapore, 1.3 percent for Japan and 1.1 percent for New Zealand. For the overall world economy, the IMF projected growth at 2.8 percent this year – 0.1 percentage point below the January update to its projection in October last year. *Source:* Khmer Times

## Cambodia's Apparel Exports to South Korea up 14 Percent

Cambodia's apparel exports to South Korea increased from $167.151 million in 2021 to $191.374 million in 2022, recording a growth of 14.37 per cent over the previous year. The exports reached $43.104 million in the first two months of 2023, close to the shipment of $43.112 million during Q4 2022. Cambodia's apparel exports recorded $169.716 million in 2020, $187.650 million in 2019 and $173.889 million in 2018. South Korea ranked 13th in Cambodia's top markets for apparel exports. The shipment to South Korea accounted for 1.37 per cent ($191.374 million) of Cambodia's total exports of $13.980 billion in 2022. Meanwhile, Cambodia was the seventh-largest apparel supplier for South Korea. Apparel imports from Cambodia accounted for 1.57 per cent of the total imports of $12.178 billion in 2022. South Korea's apparel imports were mainly from China and Vietnam, who supplied 64 per cent of the apparel to the Korean market. *Source:* Khmer Times

## Q1 Milled Rice Exports Soar to $126M on Europe Sales Uptick

Cambodia exported milled rice worth $126 million overseas in the first three months of 2023 – an increase of $20.9 million, or about 19.9 per cent, over the same period last year, according to data from the General Department of Customs and Excise of Cambodia (GDCE). CRF secretary-general Lun Yeng said that the increase of nearly 20 per cent was in the amount paid, while the quantity of rice was only about 12 per cent more. He added that the increase in the export of milled rice in the first quarter was by over 20,000 tonnes and much more fragrant rice was exported, especially to Europe. "Because Europe reopened its market, a lot of fragrant milled rice was exported as it was not taxed. Previously it was harder to sell, but now it is easy because the taxes that were being levied ended in early 2022. And the costs of transport are more affordable than before," he said. He continued that another factor in the increase in Cambodia's fragrant rice exports was that late in 2022, Cambodia's fragrant rice was ranked best in the world. *Source:* Phnom Penh Post

## Q1 China Trade Nears $2.9B as Deficit Shrinks

The merchandise trade volume between Cambodia and mainland China reached $2.862 billion in the first quarter (Q1) of 2023, marking a 0.38 per cent year-on-year drop from $2.873 billion, with imports from the East Asian market accounting for an 88.52 per cent share, down 0.28 percentage points on a yearly basis, according to provisional Customs (GDCE) data. In the January-March period, Cambodian goods exports to and imports from mainland China were to the tune of $328.646 million and $2.534 billion, respectively, up 2.13 per cent but down 0.70 per cent year-on-year from $321.787 million and $2.552 billion. This narrowed the Kingdom's trade deficit with its top trading partner for the period by 1.11 per cent on an annual basis to $2.205 billion, from $2.230 billion. Mainland China was also Cambodia's top import source for the first quarter, as well as the fourth-largest export destination, after the US ($1.823 billion), Vietnam ($909.803 million) and Thailand ($334.163 million). *Source:* Phnom Penh Post

## តើអាស៊ានអាចជាចំណុចកណ្តាលនៃកំណើនសេដ្ឋកិច្ច?

"អាស៊ានជាចំណុចកណ្តាលនៃកំណើនសេដ្ឋកិច្ច" គឺជាប្រធានបទនៃការធ្វើជាប្រធានអាស៊ានឆ្នាំ២០២៣របស់ប្រទេសឥណ្ឌូនេស៊ី។ តើវាជាចក្ខុវិស័យដែលអាចទុកចិត្តបាន និងអាចសម្រេចបានដែរឬទេ? ខណៈអ្នកខ្លះអាចមានសុទិដ្ឋិនិយមអំពីសក្តានុពលនៃចក្ខុវិស័យនេះ វាហាក់ដូចជា គ្រាមភាសាជាជាងចក្ខុវិស័យ។ តាមការពិនិត្យមើលសូចនាករសេដ្ឋកិច្ចសំខាន់ៗមួយចំនួន ដែលផ្អែកសុទិដ្ឋិនិយមអាចនឹងពិចារណាដែលធ្វើឱ្យសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) ជាចំណុចកណ្តាលនៃកំណើនសក្តានុពល។ ទីមួយ អាស៊ានបានទទួលលទ្ធផលសេដ្ឋកិច្ច និងប្រជាសាស្ត្រ ដ៏គួរឱ្យចាប់អារម្មណ៍ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ។ តំបន់នេះទទួលបានអត្រាកំណើនសេដ្ឋកិច្ចជាមធ្យម ៥% ក្នុងចំណោមតំបន់ ដែលមានអត្រាកំណើនខ្ពស់បំផុតនៅលើពិភពលោក ពីឆ្នាំ ២០០០-២០២២។ គិតត្រឹមឆ្នាំ ២០២២ ប្រជាជនអាស៊ានមានចំនួន ៦៧២ លាននាក់ ប្រហែល ៩% នៃចំនួនប្រជាជនសរុបរបស់ពិភពលោក ហើយតំបន់នេះបានរួមចំណែក ៦,៤% ដល់ផលិតផលក្នុងស្រុកសរុបសកល។ ដោយមិនរាប់បញ្ចូលទិន្នន័យពីប្រទេសកម្ពុជា អាស៊ានមានអត្រាកំណើនផលិតភាពការងារ ៣,២% ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០២២។ គួរកត់សម្គាល់ថា ដោយផ្អែកលើមធ្យមភាគសាមញ្ញសម្រាប់ឆ្នាំ២០២២ ប្រហែល ៦៨% នៃចំនួនប្រជាជននៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេទាំងប្រាំមួយនៅក្នុងតំបន់អាស៊ាន-ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ សិង្ហបុរី និងវៀតណាម ស្ថិតក្នុងចន្លោះអាយុធ្វើការពី ១៥ ទៅ ៦៤ ឆ្នាំ។ គួបផ្សំនឹងស្ថានការណ៍នយោបាយដែលមានស្ថិរភាព កត្តាទាំងនោះបានដាក់អាស៊ានជាដៃគូពាណិជ្ជកម្ម និងវិនិយោគដ៏ទាក់ទាញបំផុតមួយនៅទូទាំងពិភពលោក។ *ប្រភព៖* GMA News Online

## សេដ្ឋកិច្ចរបស់ប្រទេសចិនបានកើនឡើង ៤,៥% ក្នុងត្រីមាសទីមួយ ដែលជាកំណើនលឿនបំផុតក្នុងមួយឆ្នាំ

ការរីកចម្រើនរបស់ប្រទេសចិន បានបិតក្នុងការចាប់អារម្មណ៍ នៅពេលដែលប្រទេសនេះបើកដំណើរការឡើងវិញ បន្ទាប់ពីបានបញ្ចប់ការរឹតត្បិតដ៏តឹងរ៉ឹងបំផុតនៃស្ថានភាពកូវីដ ដែលបានធ្វើឡើងអស់រយៈពេលជិត៣ឆ្នាំ។ ផលិតផលក្នុងស្រុកសរុបនៅត្រីមាសទី១ របស់ប្រទេសចិនបានកើនឡើងយ៉ាងខ្លាំងខណៈពេលដែល សកលលោកប្រឈមមុខនឹងកំណើនយឺត ដោយសារធនាគារកណ្តាលដំឡើងអត្រាការប្រាក់ដើម្បីទប់ទល់នឹងអតិផរណា។ កាលពីថ្ងៃទី១៨ ខែមេសា ការិយាល័យស្ថិតិជាតិរបស់ប្រទេសចិនលើកឡើងថា ផលិតផលក្នុងស្រុកសរុប បានកើនឡើង ៤,៥% នៅក្នុងត្រីមាសទី១។ នេះគឺជាកំណើនខ្ពស់បំផុតចាប់តាំងពីត្រីមាសទី១នៃឆ្នាំមុន នៅពេលដែលសេដ្ឋកិច្ចរបស់ប្រទេសចិនបានកើនឡើង ៤,៨% និងប្រសើរជាងការព្យាករ ៤% នៃការស្ទង់មតិរបស់ Reuters ។ ដោយធៀបនឹងត្រីមាសមុន សេដ្ឋកិច្ចបានកើនឡើង ២,២% ។ ការរីកចម្រើនរបស់ប្រទេសចិន បានបិតក្នុងការចាប់អារម្មណ៍ ខណៈដែលប្រទេសនេះ បើកឡើងវិញបន្ទាប់ពីបញ្ចប់ការរឹតបន្តឹងនៃជំងឺកូវីដ ១៩ ដែលបានធ្វើឡើងអស់រយៈពេលជិត៣ឆ្នាំ។ សេដ្ឋកិច្ចបានកើនឡើង ២,៩% នៅក្នុងត្រីមាសទី៤ ក្នុងឆ្នាំ២០២២។ *ប្រភព៖* NBC News

## ភាពប្រាកដនៃការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោក ឆ្ពោះទៅរកមាគ៌ាមិនបិតថេរ

សេដ្ឋកិច្ចសកល កំពុងបិតនៅក្នុងដំណាក់កាលនៃការងើបឡើងវិញបន្តិចម្តងៗពីជំងឺរាតត្បាត និងពីការឈ្លានពានរបស់រុស្ស៊ីទៅលើអ៊ុយក្រែន ប៉ុន្តែមានហានិភ័យ និងមានបញ្ហាប្រឈម បើយោងតាមលោក Pierre-Olivier Gourinchas ទីប្រឹក្សាសេដ្ឋកិច្ច និងជានាយកស្រាវជ្រាវនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ថ្លែងក្នុងវេទិកាចក្ខុវិស័យសេដ្ឋកិច្ចពិភពលោកចុងក្រោយថ្មីៗនេះ។ អតិផរណាកំពុងធ្លាក់ចុះបន្តិចម្តងៗ ប៉ុន្តែកំណើនសេដ្ឋកិច្ចនៅតែទាបជាប្រវត្តិសាស្ត្រ ហើយហានិភ័យហិរញ្ញវត្ថុបានកើនឡើង ជាពិសេសនៅក្នុងវិស័យធនាគារ។ របាយការណ៍នេះផ្តល់យោបល់ថានិយតករនិងអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ គួរតែពង្រឹងការត្រួតពិនិត្យដើម្បីជៀសវាងវិបត្តិពេញលេញ ខណៈដែលអ្នកបង្កើតគោលនយោបាយត្រូវធ្វើទំនាក់ទំនងឱ្យបានច្បាស់លាស់ និងចាត់វិធានការដើម្បីគាំទ្រគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធ។ របាយការណ៍នេះក៏បានព្រមានអំពីព្រឹត្តិការណ៍ "ហានិភ័យ" ដែលអាចប៉ះពាល់ដល់លក្ខខណ្ឌឥណទាន និងហិរញ្ញវត្ថុសាធារណៈ ជាពិសេសនៅក្នុងទីផ្សារដែលកំពុងរីកចម្រើន និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍។ *ប្រភព៖* IMF Blog

## ឧស្សាហកម្ម ឬសេវាកម្ម? អាស៊ីគឺជាអ្នកគូសវាសផ្លូវអភិវឌ្ឍន៍របស់ខ្លួន

មាគ៌ាប្រពៃណីរបស់អាស៊ីឆ្ពោះទៅរកកំណើនសេដ្ឋកិច្ច តាមរយៈឧស្សាហូបនីយកម្ម ជាពិសេសក្នុងវិស័យកម្មន្តសាល មានការប្រែប្រួលកាន់តែខ្លាំងឡើងក្នុងរយៈពេលថ្មីៗនេះ ដោយសារប្រទេសជាច្រើនបានងាកទៅរកវិស័យសេវាកម្មជំនួសវិញ។ ប៉ុន្តែ កង្វះខាតនៃវិស័យកម្មន្តសាលធំៗ ត្រូវបានគេមើលឃើញថាជាគុណវិបត្តិយ៉ាងធ្ងន់ធ្ងរសម្រាប់ដំណើរការអភិវឌ្ឍ និងជាមូលហេតុដើម្បីគាំទ្រគោលនយោបាយឧស្សាហកម្ម។ វិស័យឧស្សាហកម្មអាចបង្កើនផលិតភាពសំខាន់ៗ និងបង្កើតការងារដែលមានប្រាក់ឈ្នួលខ្ពស់ និងសុវត្ថិភាពសម្រាប់កម្មករដែលមិនមានជំនាញ ដែលទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍស្មើៗគ្នា។ ខណៈពេលដែលការអំពាវនាវឱ្យមានវិធានការលើគោលនយោបាយដើម្បីគាំទ្រដល់ឧស្សាហូបនីយកម្មត្រូវបានព្រមានជាញឹកញាប់ ប្រទេសជាច្រើនប្រឈមមុខនឹងបញ្ហាដូចជា គុណភាពស្ថាប័នទាបគោលនយោបាយអភិវឌ្ឍន៍ផលិតភាពគ្មានប្រសិទ្ធភាព ឧបសគ្គទីផ្សារការងារ និងការតភ្ជាប់ពាណិជ្ជកម្មមិនពេញលេញ។ *ប្រភព៖* Asian Development Blog

## ដើម្បីសង្គ្រោះការធ្វើពាណិជ្ជកម្មសកល គេត្រូវការកែទម្រង់

រដ្ឋាភិបាល និងវិស័យឯកជនចាំបាច់ត្រូវដោះស្រាយភាពទន់ខ្សោយក្នុងការធ្វើពាណិជ្ជកម្មសកល និងខ្សែច្រវាក់ផ្គត់ផ្គង់។ សកលភាវូបនីយកម្ម និងប្រព័ន្ធពាណិជ្ជកម្មអន្តរជាតិមានការរិះគន់ជាច្រើននាពេលបច្ចុប្បន្ននេះ។ អ្នកខ្លះនិយាយថាពាណិជ្ជកម្មបង្កផលប៉ះពាល់ច្រើនជាងផលល្អ ហើយមានផលអាក្រក់សម្រាប់បរិស្ថាន ខ្វះភាពធន់ មិនមានតម្លាភាព និងមិនបានរាប់បញ្ចូលមនុស្សគ្រប់គ្នា។ វាជាការពិតដែលបរិយាកាសសេដ្ឋកិច្ចនិងនយោបាយ និងវិបត្តិអាកាសធាតុកំពុងបង្ហាញភាពទន់ខ្សោយមួយចំនួននៅក្នុងប្រព័ន្ធពាណិជ្ជកម្មសកល។ ប៉ុន្តែ បញ្ហាទាំងនោះគួរតែជាកម្លាំងរុញច្រានដើម្បីកែលម្អវា មិនមែនបោះបង់វាចោលឡើយ។ ការកែលម្អខ្សែច្រវាក់ផ្គត់ផ្គង់ និងការធ្វើពាណិជ្ជកម្មសកល មានន័យថា ធ្វើឱ្យមានភាពធន់និងបរិយាប័ន្នកាន់តែខ្លាំង ហើយអភិវឌ្ឍឆ្ពោះទៅរកអនាគតបៃតងនិងសមធម៌ជាងមុន។ *ប្រភព៖* *Asian Development Blog*

## ចក្រភពអង់គ្លេសគ្រោង នឹងចូលរួមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអន្តរប៉ាស៊ីហ្វិក

បីឆ្នាំបន្ទាប់ពីការចាកចេញពីសហភាពអឺរ៉ុប ចក្រភពអង់គ្លេសបានចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយក្រុមប្រទេសឥណ្ឌូប៉ាស៊ីហ្វិក។ ការចូលជាសមាជិករបស់ចក្រភពអង់គ្លេស ចំពោះកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយនិងរីកចម្រើនសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) មានន័យថា ចក្រភពអង់គ្លេសចូលរួមជាមួយក្លឹបនៃប្រទេសចំនួន១១ ផ្សេងទៀតដែលមានទំហំសេដ្ឋកិច្ចសរុបស្មើ១៤% នៃសេដ្ឋកិច្ចពិភពលោក។ កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយនិងរីកចម្រើនសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសជប៉ុន ម៉ាឡេស៊ី វៀតណាម អូស្ត្រាលី សិង្ហបុរី ព្រុយណេ នូវែលសេឡង់ កាណាដា ម៉ិកស៊ិក ប៉េរូ និងឈីលី។ វាគឺជាប្លុកពាណិជ្ជកម្មដ៏ធំមួយនៅក្នុងពិភពលោកដែលមានចំណែក១៥% នៃផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក នៅពេលដែលចក្រភពអង់គ្លេសចូលរួម។ *ប្រភព៖* *World Economic Forum*

### Can ASEAN be an Epicentrum of Growth?

'ASEAN as an Epicentrum of Growth' is the theme of Indonesia's 2023 ASEAN Chairmanship. Is it a reliable and attainable vision? Whilst some may be optimistic about the vision's potential, for us, it sounds more like jargon than a vision. Let's begin by examining some of key economic indicators that the optimistic side might have considered, which render Association of Southeast Asian Nations (ASEAN) as a potential epicentrum of growth. First, ASEAN has recorded impressive economic performance and demographic profile over the last two decades. The region has recorded average economic growth of 5%, amongst the highest in the world from 2000-2022. As of 2022, ASEAN's population stood at 672 million, about 9% of the world's total population, and the region contributed 6.4% to global GDP. Excluding data from Cambodia, ASEAN recorded labour productivity growth of 3.2% from 2000 to 2022. Notably, based on a simple average for the year 2022, about 68% of the population in the six largest economies in the ASEAN region—Indonesia, Malaysia, the Philippines, Thailand, Singapore, and Viet Nam— are within the working age range of 15 to 64 years old. Combined with a stable political situation, those factors place ASEAN as one of the most attractive trade and investment partners globally. *Source: GMA News Online*

### China's Economy Grew 4.5% in the First Quarter, the Fastest Pace in A Year

China's growth has been in the spotlight as the country reopens after it ended most of the strict Covid restrictions that were in place for nearly three years. China's first-quarter gross domestic product rose sharply while global peers face slowing growth as central banks hike rates to tame inflation. GDP grew by 4.5% in the first quarter, China's National Bureau of Statistics said Tuesday. That marks the highest growth since the first quarter of last year — when China's economy grew by 4.8% — and better than the 4% forecast in a Reuters poll. Quarter-on-quarter, the economy grew 2.2%. China's growth has been under the spotlight as it reopens after ending most of its strict Covid restrictions that were in place for nearly three years. The economy expanded 2.9% in the fourth quarter of 2022. *Source: NBC News*

### Global Economic Recovery Endures but the Road Is Getting Rocky

The global economy is on track for a gradual recovery from the pandemic and Russia's invasion of Ukraine, but there are risks and challenges ahead, according to Pierre-Olivier Gourinchas, the Economic Counsellor and the Director of Research of the IMF, in his latest World Economic Outlook. Inflation is falling slowly, but growth remains historically low and financial risks have risen, particularly in the banking sector. The report suggests that financial regulators and supervisors should strengthen oversight to avoid a full-blown crisis, while policymakers need to communicate clearly and take steps to support monetary and fiscal policies. The report also warns of a potential "risk-off" event that could significantly impact credit conditions and public finances, particularly in emerging market and developing economies. *Source: IMF Blog*

### Factories or Call Centers? Asia Charts its Development Path

Asia's traditional path to economic growth through industrialization, particularly in the manufacturing sector, has been increasingly uncommon in recent times, with many countries turning towards the service sector instead. However, the lack of a sizeable manufacturing sector is seen as a serious drawback for development trajectories and a reason to advocate for industrial policy. The industrial sector can produce significant productivity gains and create high-paying and secure jobs for unskilled workers, leading to a more equal distribution of development gains. While calls for policy action to support industrialization are often warranted, many countries face challenges such as low institutional quality, ineffective productive development policies, labor-market constraints, and incomplete trade links. *Source: Asian Development Blog*

### For Global Trade to Survive, It Needs an Overhaul

Governments and the private sector need to address weaknesses in global trade and supply chains. Globalization and the international trade system have many critics these days. Some say that trade does more harm than good, is bad for the environment, lacks resilience, is not transparent, and doesn't include enough people. It is true that the economic and political environment, and the climate crisis, are exposing some weaknesses in the global trading system. But that should be the impetus to improve it, not abandon it. Improving global trade and supply chains means making them more resilient and inclusive, and developing them as a vehicle for a greener and more equitable future. *Source: Asian Development Blog*

### The United Kingdom is Set to Join the Trans-Pacific Free Trade Pact

Three years after leaving the European Union, the United Kingdom has negotiated a trade pact with a band of Indo-Pacific countries. The UK's accession to the Comprehensive

and Progressive Agreement for Trans-Pacific Partnership (CPTPP) means it joins a club of 11 other countries which together generate 14% of the world's income. The CPTPP is a free trade agreement between Japan, Malaysia, Vietnam, Australia, Singapore, Brunei, New Zealand, Canada, Mexico, Peru and Chile. It is one of the biggest trading blocs in the world, worth 15% of global GDP once the UK joins. *Source: World Economic Forum*

# ការអប់រំវិជ្ជាជីវៈ និងរំហូរការវិនិយោគផ្ទាល់ពីបរទេស៖ ការវិភាគសំណុំទិន្នន័យបណ្តាប្រទេសនៅតំបន់អាស៊ីនិងអាម៉េរិកឡាទីន

**ប៊ុន វុទ្ធី**
អគ្គនាយករង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីសង្ខេប

ខណៈពេលដែលរំហូរវិនិយោគផ្ទាល់ពីបរទេស (FDI) នៅទូទាំងពិភពលោក បានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ សមាមាត្រធំបំផុតនៃរំហូរវិនិយោគផ្ទាល់ពីបរទេស បានហូរចូលទៅអាស៊ីនិងអាម៉េរិកឡាទីន។ មូលធនមនុស្សនៅក្នុងតំបន់ទាំងនេះ ត្រូវបានគេទទួលស្គាល់ថា មានជំនាញខ្ពស់ជាងកម្រិតមូលដ្ឋាន ដែលជាតម្រូវការសម្រាប់ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស។ ជាធម្មតា ការសិក្សាសំអាងលើការពិសោធន៍វាស់មូលធនមនុស្សជំនាញផ្អែកលើការសិក្សា ឬការអប់រំទូទៅ ដូចជាអត្រាចុះឈ្មោះចូលរៀននៅមធ្យមសិក្សា កម្រិតឧត្តមសិក្សា អត្រាអក្ខរកម្ម ឬឆ្នាំសិក្សាជាមធ្យម។ ក៏ប៉ុន្តែ ការអប់រំវិជ្ជាជីវៈ ដែលផ្តល់ឱ្យនិស្សិតបញ្ចប់ការសិក្សានូវចំណេះដឹងនិងជំនាញជាក់ស្តែងសម្រាប់ការងារ មិនទាន់ត្រូវបានយកមកធ្វើការសិក្សានៅឡើយទេ។ ដូច្នេះ ការសិក្សានេះ ទាញយកទិន្នន័យពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ចំនួន ៣៩ប្រទេស នៅអាស៊ីនិងអាម៉េរិកឡាទីនក្នុងអំឡុងឆ្នាំ១៩៩០-២០១៨ ដើម្បីធ្វើការពិនិត្យមើលឥទ្ធិពលនៃការអប់រំវិជ្ជាជីវៈលើរំហូរចូលទុនវិនិយោគផ្ទាល់ពីបរទេស។ ការសិក្សានេះប្រើប្រាស់ចំណែកនិស្សិតវិជ្ជាជីវៈក្នុងការអប់រំមធ្យមសិក្សា អត្រាចុះឈ្មោះចូលរៀនមធ្យមសិក្សា និងអត្រាចុះឈ្មោះចូលរៀនថ្នាក់ឧត្តមសិក្សា ជាតំណាងមូលធនមូលធនមនុស្ស។ ការវិភាគស្ថិតិ ដោយផ្អែកលើ Pooled Ordinary Least Squares (POLS) Random Effect Model (REM) Fixed Effect Model (FEM) និង Feasible Generalize Least Squares (FGLS) បង្ហាញនូវឥទ្ធិពលវិជ្ជមាននៃមូលធនមនុស្សទៅលើរំហូរចូលទុនវិនិយោគផ្ទាល់ពីបរទេស។ ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវ ការអប់រំវិជ្ជាជីវៈត្រូវបានរកឃើញថាមានឥទ្ធិពលវិជ្ជមានក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងតំបន់សិក្សាខាងដើម។ លទ្ធផលមានភាពរឹងមាំក្រោមជម្រើសលក្ខខណ្ឌផ្សេងៗ។

## សេចក្តីផ្តើម

ការសិក្សាថ្មីៗនេះបានអះអាងថា អាស៊ីនិងអាម៉េរិកឡាទីន គឺជាតំបន់ ដែលទាក់ទាញចំណែកភាគច្រើនបំផុតនៃការវិនិយោគផ្ទាល់ពីបរទេស ។ ជាងនេះទៅទៀត អ្នកស្រាវជ្រាវមួយចំនួនបានរកឃើញថា ការវិនិយោគផ្ទាល់ពីបរទេស មានទំនោរហូរចូលទៅក្នុងប្រទេសដែលមានកម្មករជំនាញ ឬក៏កម្លាំងពលកម្មប្រកបដោយផលិតភាព។ ពលករជំនាញ ជាទូទៅត្រូវបានកំណត់លក្ខណៈដោយកម្រិតនៃការអបរំ ក៏ដូចជាកម្រិតភាពជំនាញ ដែលទទួលបានតាមរយៈការបណ្តុះបណ្តាល។ ជាឧទាហរណ៍ ការអប់រំវិជ្ជាជីវៈ ផ្តល់នូវជំនាញអនុវត្តជាក់ស្តែង និងជំនាញបច្ចេកទេស សម្រាប់ការងារ និងការបង្កើនផលិតភាពការងារផងដែរ។ ក្នុងន័យនេះ ការអប់រំវិជ្ជាជីវៈ អាចមានឥទ្ធិពលក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស។ ប៉ុន្តែ ឥទ្ធិពលមួយនេះ ស្ថិតនៅក្នុងចម្ងល់សង្ស័យនៅឡើយទេ។ ហេតុដូចនេះ ទើបការសិក្សាមួយនេះដោះស្រាយនូវសំណួរស្រាវជ្រាវដែលចោទថា “តើការអប់រំវិជ្ជាជីវៈមានឥទ្ធិពលក្នុងការទាក់ទាញរំហូរការវិនិយោគពីបរទេសចូលទៅក្នុងតំបន់អាស៊ី និងអាម៉េរិកឡាទីនដែរឬទេ ?”

ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ រំហូរនៃការវិនិយោគផ្ទាល់ពីបរទេស បានហូរចូលទៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ មានការកើនឡើងខ្លាំងគួរឱ្យកត់សម្គាល់។ ការសិក្សាមួយចំនួន បានធ្វើការស៊ើបអង្កេត ថាតើការកើនឡើងនៃរំហូរការវិនិយោគផ្ទាល់ពីបរទេសចូលប្រទេសកំពុងអភិវឌ្ឍន៍ថ្មីៗនេះ ពិតជាជួយលើកកម្ពស់ដល់កំណើនសេដ្ឋកិច្ចរបស់ពួកគេដែរឬទេ។ ការសិក្សាដែលធ្វើឡើងដោយ Borensztein et al. (1998) និង Li and Liu (2005) បានរកឃើញថា ការវិនិយោគផ្ទាល់ពីបរទេសបានរួមចំណែកយ៉ាងសំខាន់ដល់កំណើន សេដ្ឋកិច្ចរបស់ប្រទេសដែលទទួលបានការវិនិយោគ។ លើសពីនេះ ការវិនិយោគផ្ទាល់ពីបរទេស ជួយបំពេញចន្លោះនៃការវិនិយោគ និងធ្វើឱ្យប្រសើរឡើងនូវផលិតភាពសេដ្ឋកិច្ចតាមរយៈការផ្ទេរបច្ចេកវិទ្យា (Keller, 2010; Liu, 2008; Miningou & Tapsoba, 2020)។

ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាមួយចំនួន បានរកឃើញថា ការវិនិយោគផ្ទាល់ពីបរទេស មិនប្រាកដថារួមចំណែកដល់ការរីកចម្រើនសេដ្ឋកិច្ច ច្រើនជាងការវិនិយោគក្នុងស្រុក សម្រាប់គ្រប់ប្រទេសម្ចាស់ផ្ទះ។ លក្ខខណ្ឌនេះអាចកើតឡើងបាន លុះត្រាតែប្រទេសម្ចាស់ផ្ទះមានមូលធនមនុស្ស ដែលមានកម្រិតអប់រំខ្ពស់បំផុតអប្បរមា។ Borensztein et al. (1998) និង Xu (2000) បានលើកទឡ្ហីករណ៍ថា ដើម្បីទទួលបានអត្ថប្រយោជន៍ពីការផ្ទេរបច្ចេកវិទ្យា និងដើម្បីបង្កើន

ផលិតភាពនៃការវិនិយោគផ្ទាល់ពីបរទេសឱ្យដល់កម្រិតអតិបរមា ប្រទេសម្ចាស់ផ្ទះ ចាំបាច់ត្រូវឈានដល់កម្រិតតម្រូវការមូលធនមនុស្សជំនាញអប្បបរមា។

ជាការពិត មូលធនមនុស្សដែលមានកម្រិតជំនាញជាក់លាក់ អាចជំរុញការវិនិយោគផ្ទាល់ពីបរទេស ក្នុងការរួមចំណែកអភិវឌ្ឍកំណើនសេដ្ឋកិច្ច ក៏ប៉ុន្តែតើមូលធនមនុស្សប្រភេទណាដែលអាចទាក់ទាញការហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេសបាន? យោងតាម Lucas (1990) និង Zhang and Markusen (1999) មូលធនមនុស្សមិនត្រឹមតែជួយជំរុញសេដ្ឋកិច្ចប៉ុណ្ណោះទេ ថែមទាំងដើរតួរយ៉ាងសំខាន់ក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស។ លើសពីនេះទៅទៀត ការដែលមានមូលធនមនុស្សដែលមានកម្រិតអប់រំកាន់តែខ្ពស់ ជាពិសេស កម្មករជំនាញ គឺជាកត្តាអំណោយផលក្នុងការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស (Kinda, 2013; Lucas, 1990; Noorbakhsh et al., 2001)។ Lucas (1990 ) បានធ្វើសេចក្តីពន្យល់ថាមូលធនមនុស្សដែលមានកម្រិតខ្ពស់ អាចជួយធ្វើឱ្យមូលធនជាក់លាក់ កាន់តែមានផលិត ភាពក៏ប្រហែលមកពី កម្មករជំនាញខ្ពស់ ជាអ្នករួមចំណែកក្នុងការបង្កើនផលិតភាព។

ផ្អែកតាមការសិក្សាខាងលើ យើងអាចសន្និដ្ឋានបានថា មូលធនមនុស្សដែលមានកម្រិតជំនាញអប្បបរមា អាចបង្កើនការរួមចំណែករបស់ការវិនិយោគផ្ទាល់ពីបរទេស ចំពោះកំណើនសេដ្ឋកិច្ចជាអតិបរមា ក៏ប៉ុន្តែ មូលធនមនុស្សត្រូវតែជាកម្មករជំនាញ ដើម្បីទាក់ទាញការហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស។ ដូច្នេះ សំណួរលើកឡើងថា តើការអប់រំកម្រិតណាដែលបង្ហាញកម្រិតកំណត់អប្បបរមា ក្នុងការកំណត់កម្លាំងពលកម្មជំនាញ ដែលមានឥទ្ធពិលយ៉ាងខ្លាំងទៅលើការហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស? បើយោងតាម Cleeve et al. (2015) កម្រិតមធ្យមសិក្សាហាក់ដូចជាកម្រិតអប្បបរមា ដែលបរិបូរណ៌សម្រាប់ជំរុញការវិនិយោគផ្ទាល់ពីបរទេសដែលស្វែងរកស័ក្តិសិទ្ធិភាព។ ក៏ប៉ុន្តែការសិក្សាសំអាងលើការពិសោធន៍ ដែលធ្វើឡើងដោយ Siddiqui and Rehman (2017) បានរកឃើញថា មធ្យមសិក្សាមិនមានឥទ្ធិពលទៅលើ អត្រាកំណើន ឬកម្រិតនៃផលិតផលក្នុងស្រុកសរុប នៅក្នុងប្រទេសអាស៊ីខាងត្បូងណាមួយនោះទេ ខណៈពេលដែលមធ្យមសិក្សាវិជ្ជាជីវៈមានឥទ្ធិពលធ្វើឱ្យមានកំណើននោះ។ ទន្ទឹមនឹងនេះ ឥទ្ធិពលការអប់រំវិជ្ជាជីវៈទៅលើរំហូរវិនិយោគផ្ទាល់ពីបរទេស នៅតែជាអាថ៌កំបាំង។ ហេតុដូចនេះ ការសិក្សានេះមានគោលបំណងបំពេញបន្ថែមនូវចន្លោះនៃការសិក្សាស្រាវជ្រាវ ដែលមានកន្លងមកទាក់ទងនឹងឥទ្ធិពលនៃការអប់រំវិជ្ជាជីវៈ ទៅលើរំហូរវិនិយោគផ្ទាល់ពីបរទេសចូលទៅតំបន់អាស៊ីនិងអាម៉េរិកឡាទីន។

បន្ទាប់ពីនេះទៅ ការសិក្សានេះត្រូវបានរៀបចំជាផ្នែកៗដូចជាៈ ការរម្លឹកឡើងវិញនូវប្រវត្តិទ្រឹស្តី និងការពិសោធន៍ ត្រូវបានបង្ហាញនៅក្នុងផ្នែកទី២។ ផ្នែកទី៣ នឹងបង្ហាញអំពីគំរូដែលយកមកអនុវត្តនៅក្នុងការសិក្សានេះ ព្រមទាំងពិពណ៌នាអំពីទិន្នន័យ និងប្រភពរបស់វាផងដែរ។ លទ្ធផលផ្អែកលើការពិសោធន៍ ត្រូវបានបង្ហាញ និងពិភាក្សានៅក្នុងផ្នែកទី៤។ សេចក្តីសង្ខេបនិងសេចក្តីសន្និដ្ឋានរបស់ការសិក្សានេះត្រូវបានបង្ហាញនៅក្នុងផ្នែកទី៥។

ដើម្បីអានខ្លឹមសារទាំងស្រុង សូមស្កេន QR កូដ

ឬចុចលើតំណភ្ជាប់ខាងក្រោម

ឯកសារពិគ្រោះលេខ ០០៣/២០២៣

*© រក្សាសិទ្ធិដោយវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ។ ខ្លឹមសារនៃអត្ថបទនេះជាគំនិតនិងទស្សនៈរបស់អ្នកនិពន្ធផ្ទាល់ និងមិនបញ្ជាំងពីទស្សនៈរបស់ក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធឡើយ។*

Research Article

# Vocational Education and FDI Inflow: A Cross-Country Panel Data Analysis of Asian and Latin-American Countries

**Bun Vuthy**
Deputy Director General
Ministry of Labour and Vocational Training

## ABSTRACT

While global foreign direct investment (FDI) flows have increased dramatically in the last few decades, the greatest proportion has been to Asia and Latin America. It has been argued that human resources in these regions have gone beyond the basic level of skills required for attracting FDI. Empirical studies commonly proxy skilled human capital in the form of academic or general education, such as secondary-enrolment rate, tertiary-enrolment rate, literacy rate, or average years of schooling. Nevertheless, vocational education, which provides graduates with the required knowledge and practical skills for employment, had not yet been studied. Therefore, drawing data from 39 developing countries in Asia and Latin America over the 1990–2018 period, this paper examines the effects of vocational education on FDI inflows. This study employs as proxies for human capital the share of vocational students in secondary education, secondary education enrolment rates, and tertiary education enrolment rates. Statistical analysis, based on Pooled Ordinary Least Squares (POLS), Random Effect Model (REM), Fixed Effect Model (FEM) and Feasible Generalized Least Squares (FGLS), reveals a positively significant effect of human capital on FDI inflows. Responding to the research question, vocational education is found to have a positive influence in attracting FDI in the regions. The results are robust under controls for alternative specifications.

## INTRODUCTION

Recent studies have claimed that Asia and Latin America are the regions attracting most of the share of foreign direct investment (FDI). Furthermore, a number of researchers have found that FDI tends to flow into a country possessing skilled workers or a productive workforce. Skilled labour is generally characterized by the level of education, as well as expertise levels, acquired through training. For instance, vocational education provides practical and technical skills for employment as well as improving labour productivity. In this regard, vocational education may have an impact in attracting FDI. However, this impact remains in question. This study, therefore, addresses the research question "Does vocational education have an impact in attracting FDI inflow into Asia and Latin America?"

In the last few decades, there has been a dramatic increase in the inflow of FDI to developing countries. A number of studies have investigated whether the recent surge in FDI inflows to developing countries enhances their economic growth. Studies conducted by Borensztein et al. (1998) and Li and Liu (2005) found that FDI significantly contributes to the economic growth of the FDI-recipient countries. In addition, FDI helps fill the investment gap and improve the productivity of the economy through technology transfer (Keller, 2010; Liu, 2008; Miningou & Tapsoba, 2020).

However, some studies have found it does not hold for all recipient countries that FDI contributes more to growth than domestic investment. This condition is true only when the host country has a minimum threshold of stock of human capital. Borensztein et al. (1998) and Xu (2000) argued that in order to benefit from technology transfer and to maximize the productivity of FDI, the host country needs to reach a minimum human-capital threshold.

Certainly, a particular level of human capital stimulates FDI contribution to growth, yet what kind of human capital can attract FDI inflow? According to Lucas (1990) and Zhang and Markusen (1999), human capital not only stimulates the economy, but also plays an essential role in attracting inward FDI. Furthermore, the availability of higher levels of human capital, particularly in the form of skilled workers, is a favourable factor in attracting FDI (Kinda, 2013; Lucas, 1990; Noorbakhsh et al., 2001). Lucas (1990) explained that a high level of human capital can make physical capital more productive because high-skilled workers are likely to contribute to increased productivity.

Based on the above studies, we can conclude that a minimum threshold of human capital maximizes the FDI contribution to growth, but human capital has to be in the form of a skilled workforce in order to attract FDI inflow. Thus, the question arises: which level of education indicates the minimum threshold for a skilled labour force to significantly affect the inflow of FDI? According to Cleeve et al. (2015), secondary-school level of education seemed to be the absolute minimum necessary to stimulate efficiency-seeking FDI. In contrast, an empirical study by Siddiqui and Rehman (2017) found that secondary education does not affect either the levels or growth rates of GDP in any South Asian country, while secondary vocational education does. Meanwhile, the effect of vocational education on FDI inflow remains a mystery. Therefore, this study aims to shed light on the gap in existing literature on the impact of vocational education on FDI inflow into Asian and Latin American countries.

The rest of this paper is structured as follows. A review of the theoretical and empirical background is presented in Section 2. Section 3 presents the model applied to the study, describes the data and their sources. Empirical results are presented and discussed in Section 4. The study's summary and conclusions are presented in Section 5.

To reach the full content of this article, please scan QR code or click the link bellow:

iTrade Working Paper No. 003/2023

*© All use subject to Trade Training and Research Institute (TTRI). The views expressed here are of the authors and do not reflect that of the Ministry of Commerce and their affiliated organizations.*

# ABOUT THE iTRADE BULLETIN

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world. This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.


**Honorable President**
H.E. Mr. PAN Sorasak

**Editorial Board**
- H.E. Mrs. CHAM Nimul (Chairwoman)
- H.E. Ms. SEREI Borapich
- Mr. HOR Iengchhay
- Mr. SOK Bunthorn

**Technical Team**
- Mr. PAO Phireak
- Ms. PHAL Yita
- Mr. CHINKET Tola
- Ms. YANGNY Chakriya
- Mr. LY Rithy
- Mr. NY Atykunn
- Mr. KHAM Chansopheak

**Advisor**
- H.E. Mr. SIM Sokheng
- H.E. Mr. SAMHENG Bora
- H.E. Mr. PENN Sovicheat
- H.E. Dr. TAT Puthsodary
- H.E. Prof. Shandre Mugan THANGAVELU

**Supporting Team Member**
- Ms. CHEA Kunlak
- Mr. SE Sokunvathna
- Ms. VAT Vanpanhapich
- Ms. VUTHY Sophanika


# ANNOUNCEMENT

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

**Topics Covered:**

- International trade and logistics / trade laws;
- Digital economy / e-commerce;
- Economics and economic laws;
- Value added supply chains and logistics; and
- Facilitate the green business transition

**Categories:**

- Research articles
- Case reports
- Policy Briefs
- Commentaries or editorial


## Trade Training and Research Institute

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla,
Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

ttri.moc | www.ttri.moc.gov.kh | @ttrimoccambodia